# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៣៤ អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពី

## ការប្តូរឈ្មោះ និងដំឡើងឋានៈ វិទ្យាស្ថានយោធាកម្ពុជា ទៅជាសាកលវិទ្យាល័យការពារជាតិ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានប្តូរឈ្មោះ និង ដំឡើងឋានៈវិទ្យាស្ថានយោធាកម្ពុជា ទៅជាសាកលវិទ្យាល័យការពារជាតិ ហៅកាត់ជាភាសាខ្មែរ "ស.ក.ជ" ជាភាសាអង់គ្លេស "National Defense University" ហៅកាត់ជាភាសាអង់គ្លេស "N.D.U." ។ សាកលវិទ្យាល័យនេះ មានទីតាំងបច្ចុប្បន្ន នៅក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**មាត្រា ២.-**

សាកលវិទ្យាល័យការពារជាតិ មានតួនាទីជាអង្គភាពបណ្តុះបណ្តាលធនធានមនុស្ស លើវិស័យការពារជាតិ ស្រាវជ្រាវយុទ្ធសាស្ត្រ វិទ្យាសាស្ត្របច្ចេកទេសយោធា ភាសា និងចំណេះដឹងទូទៅ ដើម្បីលើកកម្ពស់គុណភាព សមត្ថភាព នាយទាហាននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីរាជការដែលមានការពាក់ព័ន្ធ លើវិស័យការពារជាតិ ។

**មាត្រា ៣.-**

សាកលវិទ្យាល័យការពារជាតិ មានឋានៈស្មើនឹងអគ្គនាយកដ្ឋាន និង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិ ។សាកលវិទ្យាល័យការពារជាតិ ដឹកនាំដោយសាកលវិទ្យាធិការមួយរូប និងសាកលវិទ្យាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤.-**

សាកលវិទ្យាល័យការពារជាតិ ធ្វើការបណ្តុះបណ្តាលកម្រិត បរិញ្ញាប័ត្ររង បរិញ្ញាប័ត្រ បរិញ្ញាប័ត្រជាន់ខ្ពស់ និងបណ្ឌិត ។ សាកលវិទ្យាល័យការពារជាតិ ត្រូវរៀបចំកម្មវិធីសិក្សាគ្រប់កម្រិត និងគ្រប់មុខជំនាញ ដោយមានការឯកភាពពីក្រសួងការពារជាតិ និងមានការទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥.-**

សាកលវិទ្យាល័យការពារជាតិ មានមហាវិទ្យាល័យចំនួន ប្រាំ (៥) ÷

១. មហាវិទ្យាល័យការពារជាតិ

២. មហាវិទ្យាល័យបញ្ជាការ-សេនាធិការ

៣. មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងភាសា

៤. មហាវិទ្យាល័យអប់រំចិត្តសាស្ត្រ និងស្រាវជ្រាវវិទ្យាសាស្ត្រយោធា

៥. មហាវិទ្យាល័យព័ត៌មានវិទ្យា និងភស្តុភាហិរញ្ញវត្ថុយោធា

ទៅអនាគត យោងតាមសេចក្តីត្រូវការចាំបាច់ក្នុងវិស័យការពារជាតិ សាកលវិទ្យាល័យនេះ អាចបើកសាខាមហាវិទ្យាល័យ ឬ មុខជំនាញផ្សេងទៀត ដោយអនុលោមតាមមាត្រា៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ៦.-**

លក្ខខណ្ឌជ្រើសរើសនិស្សិត ឱ្យចូលសិក្សានៅសាកលវិទ្យាល័យការពារជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ដោយសម្របសម្រួលទៅតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការកំណត់លក្ខខណ្ឌ នៃការចូលរៀននៅឧត្តមសិក្សា និង ការណែនាំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ស្របតាមមាត្រា ២៩ និង មាត្រា ៣៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ។

**មាត្រា ៧.-**

និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យការពារជាតិ និងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រតាមកម្រិត និងតាមមុខជំនាញដែលបានសិក្សា ។

សញ្ញាប័ត្រនេះ នឹងចុះហត្ថលេខាដោយសាកលវិទ្យាធិការ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨.-**

ក្រសួងការពារជាតិ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការក្នុងការរៀបចំកម្មវិធីសិក្សា និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន នៅសាកលវិទ្យាល័យការពារជាតិ តាមតម្រូវការ និង ភារកិច្ចកសាងធនធានមនុស្សលើវិស័យការពារជាតិ ។

**មាត្រា ៩.-**

ការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅនៃសាកលវិទ្យាល័យការពារជាតិ និងអង្គភាពចំណុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និង សាកលវិទ្យាល័យការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ